ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០១ [illegible]

ភ្នំពេញ ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ ២០០៧

សេចក្តីសម្រេច
ស្តីពី
ការដាក់ឱ្យប្រើប្រាស់បទដ្ឋានចំណតរថយន្ត និងទោចក្រយានយន្ត

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាសាងសង់
- យោងស្មារតីអង្គប្រជុំពិគ្រោះយោបល់អន្តរក្រសួងនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៦
- យោងតាមការចាំបាច់ ។

សម្រេច

ប្រការ១ : ដាក់អោយប្រើប្រាស់ជាទូទៅនូវបទដ្ឋានចំណតរថយន្ត និង ទោចក្រយានយន្តសំរាប់ទីក្រុង និងទីប្រជុំជនគ្រប់ខេត្តក្រុងដូចមានចែងក្នុងឧបសម្ព័ន្ធនៃសេចក្តីសំរេចភ្ជាប់ជាមួយ ។

ប្រការ២ : បទដ្ឋានចំណតរថយន្ត និង ទោចក្រយានយន្ត នេះសំរាប់អនុវត្តក្នុងបរិវេណដីឡូត៍ និងក្រៅពីផ្លូវសាធារណៈ ។ ការសុំសាងសង់ថ្មី ការផ្លាស់ប្តូរមុខងារសំណង់ និង ការផ្តល់លិខិតអនុញ្ញាតសាងសង់ត្រូវគោរពតាមបទដ្ឋាននេះ ។

ប្រការ៣ : ចំនួនចំណតដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចភ្ជាប់ជាមួយនេះជាចំនួនឬទំហំអប្បបរមាដែលត្រូវមានជាចាំបាច់ ។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនចំណតត្រូវយកចំនួនគត់ដែលមានតំលៃធំជាងបន្ទាប់នៃលទ្ធផល ។

ប្រការ៤ : សេចក្តីសំរេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និង ដឹកជញ្ជូន ,
- គ្រប់សាលាខេត្ត-ក្រុង ,
- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធនៃក្រសួង ដ.ន.ស
- គ្រប់មន្ទីរ ដ.ន.ស.ស.ខេត្ត ក្រុង " ដើម្បីសហការអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ